# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចព្រមព្រៀង
## រវាង
## នាយករោងចក្រ គ្លរី និតវែរ អិលធីឌី
## និង
## តំណាងប្រតិភូបុគ្គលិក តំណាងកម្មករ និងសហជីពសាមគ្គីភាព
## ស្តីអំពីការព្យួរកិច្ចសន្យាការងារ

នៅថ្ងៃទី ០៩ខែ តុលា ឆ្នាំ២០២១ វេលាម៉ោង ១០:០៥នាទីថ្ងៃ នៅក្នុងរោងចក្រ គ្លរី និតវែរ អិលធីឌី មានកិច្ចប្រជុំមួយនៅក្នុងរោងចក្រ រវាងតំណាងរោងចក្រ និង តំណាងកម្មករ និយោជិតសហជីពមូលដ្ឋាន ប្រចាំរោងចក្រ ។

នៅក្នុងអង្គប្រជុំនេះលោកនាយករោងចក្រឈ្មោះ **DAI BIN** ជូនដំណឹង ដល់កម្មករនិយោជិតទាំងអស់អំពីស្ថានភាពបច្ចុប្បន្នថា ដោយសារតែរោងចក្រយើងគ្មានអ្នកបញ្ជាទិញទំនិញគ្រប់គ្រាន់ ដែលជាហេតុធ្វើឲ្យរោងចក្រគ្មានលទ្ធភាពគ្រប់គ្រាន់សម្រាប់បើកប្រាក់ខែឲ្យកម្មករ ហេតុដូចនេះរោងចក្រសម្រេចធ្វើការព្យួរកិច្ចសន្យាការងារ របស់កម្មករនិយោជិត ចំនួន ១៧១នាក់ ដែលមានរយះពេលចំនួន15ថ្ងៃគឺចាប់ពីថ្ងៃទី **២៦ ខែ ១០ ឆ្នាំ២០២១ រហូតដល់ថ្ងៃទី ០៩ ខែ ១១ ឆ្នាំ២០២១** ។ នៅក្នុងអំឡុងពេលនៃការព្យួរការងារនេះ កម្មករនិយោជិតបានឯកភាពទទួលយកនូវការផ្តល់ជូនរបស់រោងចក្រនូវ ប្រាក់ឧបត្ថម្ភចំនួន ២០ដុល្លារ និង ប្រាក់ឧបត្ថម្ភចំនួន៣០ដុល្លារអាមេរិក ទទួលបានពីរាជរដ្ឋាភិបាល សរុបទាំងអស់ចំនួន ៥០ដុល្លារអាមេរិក (ក្នុងករណីមិនទទួលបានការជួយឧបត្ថម្ភពីរាជរដ្ឋាភិបាលទេ ជាបន្ទុករបស់រោងចក្រ) សម្រាប់កម្មករម្នាក់ៗ ក្នុងកន្លះខែ ។

អង្គប្រជុំបានចប់វេលាម៉ោង ១០:៥០នាទីនាថ្ងៃខែឆ្នាំដដែលប្រកបដោយ ភាពស្និតស្នាល និងយោគយល់គ្នាក្រោមស្មារតីទទួលខុសត្រូវ ។

បែកចាន. ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០២១

នាយកក្រុមហ៊ុន

DAI BIN

តំណាងសហជីព

ប្រធាន ល. ស៊ឹម កុសល　　អនុប្រធាន ល. ស៊ុក សាត

តំណាងកម្មករ

ល. សេងកុសល　ល. ស៊ឹម កុសល　ល. ស៊ុក សាត　ល.ស រឿន សុភាព

ល.ស រឿន សុផាត　ល.ស សេក ចាន់ធូ　ល.ស ឃុត ទំព័រ　ល.ស សៀក ចាន់ថា

ល.ស រឿន សុឃីម　ល. តាំង អៀងហៀង　ល. លី ឆយ